**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃពុធ ២រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មានស្តីពី
# ពិធីដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម
# តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី២

ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ២ នឹងត្រូវដាក់ឱ្យដំណើរការជាផ្លូវការ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៩:០០ ព្រឹក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការចូលរួមពីក្រសួង-ស្ថាប័នចូលរួមក្នុងការងារចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានដំណាក់កាលទី១ និងដំណាក់កាលទី ២ តំណាងសមាគម អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ ស្ថានទូត និងគ្រឹះស្ថានសិក្សាផងដែរ។

គួរបញ្ជាក់ដែរថា ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន គឺជាការកែទម្រង់មុតស្រួចជាកញ្ចប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញ ក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៨ កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ កន្លងទៅ ។ ក្នុងដំណាក់កាលទី ១ ប្រព័ន្ធបានគ្របដណ្តប់លើការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម, ការចុះបញ្ជីពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារ និងការផ្តល់សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។ ដោយឡែក, ក្នុងដំណាក់កាលទី២ នេះ, ប្រព័ន្ធនឹងពង្រីកវិសាលភាពដល់ការស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតផ្សេងៗតាមអនឡាញ ទៅតាមសកម្មភាពអាជីវកម្ម ពីក្រសួង-ស្ថាប័នជំនាញដែលមានតួនាទីត្រួតពិនិត្យផ្នែកបច្ចេកទេសតាមវិស័យ។ ក្នុងនោះ, ក្រសួង-ស្ថាប័នចំនួន ៤ បានចូលរួមក្នុងដំណាក់កាលទី ២ នេះ រួមមាន៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ក្នុងន័យនេះ, សូមសាធារណជន និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់មេត្តា **តាមដានការផ្សាយផ្ទាល់** នូវពិធីដាក់ដំណើរការជាផ្លូវការ នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់-កាលទី ២ កុំបីអាក់ខាន **នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៩:០០ ព្រឹក លើទំព័រហ្វេសប៊ុករបស់**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( https://www.facebook.com/ministry.economy.finance/ )។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

Phnom Penh, 25 August 2021

**Press Release**
**on the Official Launch Ceremony of the Business Registration System**
**on Information Technology Platform Phase II**

The Business Registration System on Information Technology Platform (OBR) Phase 2 will be officially launched on September 1, 2021 at 9:00am presiding over by His Excellency **Dr. AUN PORNMONIROTH, Deputy Prime Minister, Minister of Economy and Finance and Chairman of the Committee on Economic and Financial Policy**. The ceremony will be attended by representatives of participating ministries of the Phase 1 and Phase 2, business associations, civil society organizations, development partners, embassies and educational institutions.

The OBR Phase 2 is a sharp reform package of **Samdech Akka Moha Sena Padei Techo HUN SEN**, **Prime Minister of the Kingdom of Cambodia**, announced in the $18^{th}$ government-private sector forum on March 29, 2019. The first phase, which was launched on June 15, 2020, covers the business registration at the Ministry of Commerce, tax registration at the General Department of Taxation, as well as the notification of enterprise opening at the Ministry of Labour and Vocational Training. This second phase expands its scopes to the online application of license or permit based on business activities, with specialized ministries in charge of sector-based technical supervision. There are four ministries/institutions participating in this second phase, including the Ministry of Industry, Science, Technology and Innovation, the Ministry of Tourism, the Ministry of Post and Telecommunications, the Real Estate Business & Pawnshop Regulator of the Non-Bank Financial Services Authority.

In this regard, you and all national and international press are invited to **watch live the virtual, official launch ceremony of the OBR Phase 2 on September 1, 2021 at 9:00am via the Ministry of Economy and Finance's Facebook page (https://www.facebook.com/ministry.economy.finance).**